# សន្លឹកព័ត៌មានសាធារណៈ

Ottawa County Health Department

## រោគវីរុសរលាកស្រោមខួរ [VIRAL MENINGITIS]

**តើរោគរលាកស្រោមខួរគឺជាអ្វី?**

ជម្ងឺមួយ កើតមកពីវីរុស ដែលពាក់ព័ន្ធនូវជាលិកាជុំវិញខួរក្បាល និងខួរឆ្អឹងខ្នង ។

**តើរោគរលាកស្រោមខួរ ត្រូវបានឆ្លងតាមរបៀបអ្វី?**

រោគរលាកស្រោមខួរអាចឆ្លងបាន តាមរបៀបទាំងឡាយខាងក្រោមនេះ:

- ដំណក់ទឹកតូចល្អិតនៅក្នុងខ្យល់ មកពីច្រមុះ ឬបំពង់កនៃអ្នកមានមេរោគវីរុស ។
- ប៉ះពាល់លាមកមានមេរោគវីរុស ។

**តើអាចមានរោគសញ្ញាអ្វីខ្លះ?**

រោគសញ្ញាអាចមានរួមទាំង:

- ក្តៅខ្លួន
- ឈឺក្បាលយ៉ាងធ្ងន់
- រឹងសរសៃក
- ពន្លឺភ្លឺធ្វើឱ្យឈឺភ្នែក
- ងងុយដេក ឬច្របូកច្របល់ក្នុងអារម្មណ៏
- ក្អួត/ចង់ក្អួត
- ក្នុងទារក – ក្តៅខ្លួន មួម៉ៅ ពិបាកដាស់ពីដំណេក ឬមិនព្រមញុំា ។

**តើរោគរលាកស្រោមខួរក្បាលត្រូវបានវិនិច្ឆ័យរោគយ៉ាងដូចម្តេច?**

ដោយការពិនិត្យទឹកឆ្អឹងខ្នងនៅក្នុងមន្ទីរពិសោធន៍ ។

**តើរោគរលាកស្រោមខួរត្រូវបានព្យាបាលយ៉ាងដូចម្តេច?**

គ្មានវិធីព្យាបាលពិតប្រាកដទេ ។ អ្នកជម្ងឺភាគច្រើន ជាដោយខ្លួនឯង ។ការសម្រាក ការផឹកទឹកច្រើន ហើយ និងការព្យាបាលកំដៅខ្លួន នោះត្រូវបានអនុសាស ។

**សម្រាប់ព័ត៌មានបន្ថែមអំពីរោគវីរុសរលាកស្រោមខួរៈ**

Ottawa County Health Department
www.miOttawa.org
Medline Plus/National Institutes of Health
www.nlm.nih.gov/medlineplus/ency/article/000680.htm

12251 James St., Suite 400
Holland, MI 49424
ទូរស័ព្ទ: (616) 396-5266
ទូរសារ: (616) 393-5643
វ៉ិបសាយ: www.miOttawa.org